ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការពារជាតិ

# សេចក្តីថ្លែងការណ៍

ក្រសួងការពារជាតិ នៃព្រះរាជាណាចក្រកម្ពុជា សូមសម្តែង ការសោកស្តាយ យ៉ាងខ្លាំង ចំពោះរបាយការណ៍បំភ្លៃការពិតដែលបង្កើតឡើង តាមអំពើចិត្តដោយ របស់ដែលហៅថា អង្គការឃ្លាំមើលសិទ្ធិមនុស្ស (HRW) ផ្សព្វផ្សាយ នៅថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលមានបំណងញុះញង់ចោទប្រកាន់ដោយគ្មានមូលដ្ឋាន និងមិនសមហេតុផល មកលើមន្ត្រីជាន់ខ្ពស់១២រូប នៃកងកម្លាំងប្រដាប់អាវុធ ព្រះរាជាណាចក្រកម្ពុជា។

ការប្រឌិតរបាយការណ៍បែបឆ្លុតលីលា របស់ក្រុមនេះ គឺជាការរំលោភបំពានម្តងហើយម្តងទៀត មកលើអធិបតេយ្យភាព ឯករាជ្យភាព និង នីតិរដ្ឋរបស់ ព្រះរាជាណាចក្រកម្ពុជា ដើម្បីបម្រើនយោបាយទុច្ចរិត របស់ជនបរទេសមួយចំនួន និងក្រុមអ្នកនយោបាយក្បត់ជាតិ ដែលបានប៉ុនប៉ង បង្កើតបដិវត្តន៍ពណ៌ បំផ្លិចបំផ្លាញដល់សន្តិភាព និងសេចក្តីសុខរបស់ប្រជាពលរដ្ឋខ្មែរ ហើយបើទោះបីជា ផែនការបដិវត្តន៍ពណ៌នេះ បានបរាជ័យរហូតដល់មានការចាប់ខ្លួនមេខ្លោងរួចហើយក៏ដោយ ក៏ក្រុមនេះខ្លះ នៅមិនទាន់បោះបង់ចោលគំនិត បំផ្លិចបំផ្លាញជាតិកម្ពុជា នៅឡើយទេ។

ក្រសួងការពារជាតិ សូមប្រកាសច្រានចោលទាំងស្រុង មិនទទួលយកដាច់ខាត ចំពោះការចោទប្រកាន់នៃរបាយការណ៍ដែលបង្កប់ឧបាយកលពិសពុល របស់ក្រុមដែលហៅថា អង្គការឃ្លាំមើលសិទ្ធិមនុស្ស បែបនេះ។

ក្រសួងការពារជាតិ សូមអំពាវនាវដល់ របស់ដែលហៅថា អង្គការឃ្លាំមើលបញ្ហាសិទ្ធិមនុស្ស (HRW) ឱ្យបញ្ឈប់ជាបន្ទាន់ នូវការប្រឌិត របាយការណ៍ចោទប្រកាន់គ្មានមូលដ្ឋាន មកលើថ្នាក់ដឹកនាំ កងកម្លាំងប្រដាប់អាវុធកម្ពុជា យ៉ាងអយុត្តិធម៌ បែបនេះតទៅទៀត៕

*ថ្ងៃព្រហស្បតិ៍ ១រោច ខែបឋមាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២*
*រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨*